ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

Ministry of Commerce

No. ១៦៧ MOC / SM 2013

THE GARMENT MANUFACTURERS ASSOCIATION IN CAMBODIA (GMAC)
THE SECRETARIAT
IN
No : 220
Date: 27.05.13 Time: 3:20
For : Mr. Van

# ប្រកាស

## ស្តីពី

## ការកែសម្រួលនីតិវិធីចេញវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ

*****

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងប្រកាសរួមលេខ ៩៨៥ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ ១.-**

ត្រូវបានធ្វើបច្ចុប្បន្នភាពនីតិវិធីនៃការចេញវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ សម្រាប់ការនាំចេញទំនិញពីកម្ពុជាទៅកាន់ទីផ្សារពិភពលោក ដែលបានកំណត់ដោយប្រកាសរបស់ក្រសួងពាណិជ្ជកម្មក្នុងពេលកន្លងទៅសំដៅសម្រួលដល់ការធ្វើពាណិជ្ជកម្ម និងឱ្យមានអនុលោមភាពតាមវិធានប្រភពដើមទំនិញរបស់ប្រទេសនាំចូល ។



ក្រសួងពាណិជ្ជកម្ម
លេខ ១៩-៦១ ផ្លូវក្រសួងពាណិជ្ជកម្ម (ផ្លូវ១១៣បេ)
ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨៦៦ ០៨៨/៨៦៦ ៩៧៨
ទូរសារលេខ: (៨៥៥) ២៣ ៨៦៦ ៩២៥
អ៊ីម៉ែល: moccab@moc.gov.kh

**ប្រការ ២.-**

ក្រុមហ៊ុន និងអ្នកនាំចេញទាំងឡាយ ដែលមានបំណងនាំទំនិញចេញពីកម្ពុជា ត្រូវមកចុះឈ្មោះទទួលសិទ្ធិនាំចេញទំនិញ នៅនាយកដ្ឋានជំនាញនៃក្រសួងពាណិជ្ជកម្ម តាមបញ្ញត្តិជាធរមាន។ ចំពោះក្រុមហ៊ុន និងអ្នកនាំចេញដែលមាន បំណងនាំចេញទំនិញផ្សេងៗ ក្រៅពី កសិផល សម្លៀកបំពាក់ វាយនភ័ណ្ឌ ស្បែកជើង ជាដើម ត្រូវភ្ជាប់មកជាមួយពាក្យសុំ នូវឯកសារពាក់ព័ន្ធ និងតារាងថ្លៃដើមនៃធាតុផ្សំ (Breakdown cost) នៃផលិតផលនាំចេញ ដើម្បីអាចគណនាពីអនុលោម ភាពនៃផលិតផលនោះ ជាមួយនឹងវិធានប្រភពដើមទំនិញ ដែលកំណត់ដោយប្រទេសផ្តល់សម្បទានពន្ធគយ។

**ប្រការ ៣.-**

ក្រុមហ៊ុន និងអ្នកនាំចេញទាំងឡាយ ដែលនាំទំនិញចេញពីកម្ពុជាទៅកាន់ទីផ្សារពិភពលោក ទោះជាស្ថិត ឬ មិនស្ថិតក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ដែលកម្ពុជាទទួលបានពីប្រទេសផ្តល់ភាពអនុគ្រោះពាណិជ្ជកម្ម ត្រូវមកដាក់ពាក្យស្នើ សុំវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ នៅនាយកដ្ឋានជំនាញនៃក្រសួងពាណិជ្ជកម្ម ឬនៅច្រកចេញ-ចូលតែមួយប្រចាំនៅ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬនៅការិយាល័យតំណាងរបស់ក្រសួងពាណិជ្ជកម្មប្រចាំតំបន់សេដ្ឋកិច្ចពិសេសនានា នៅទូទាំង ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៤.-**

នីតិវិធីនៃការដាក់ពាក្យស្នើសុំវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ ត្រូវកំណត់ដូចខាងក្រោម :

១- **ការនាំចេញតាមជើងនាវា (By Sea)**

ក- *ទំនិញសម្លៀកបំពាក់ ផលិតផលវាយនភ័ណ្ឌ ស្បែកជើង និងសំភារៈប្រើប្រាស់ផ្សេងទៀត (Apparels) ដូចជា កាបូប មួក ជាដើម*

- ពាក្យស្នើសុំវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញរបស់ក្រុមហ៊ុន
- មូលប្បទានប័ត្រថតចម្លង បញ្ជាក់ពីការបានបង់សោហ៊ុយរដ្ឋបាល និងកម្រៃគ្រប់គ្រងការនាំចេញ
- បង្កាន់ដៃបង់ប្រាក់កម្រៃសេវាសាធារណៈ
- វិក័យប័ត្រទិញ-លក់ (Invoice)
- តារាងបញ្ជាក់ពីការវេចខ្ចប់ (Packing List)
- អញ្ញត្តិប័ណ្ណដឹកជញ្ជូន (Bill of Lading)
- កំណត់ហេតុរួមស្តីពីការត្រួតពិនិត្យទំនិញវាយនភ័ណ្ឌនាំចេញ របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និង អគ្គនាយកដ្ឋានកាំកុងត្រូល
- ប្រតិវេទន៍ចេញពីកម្ពុជា (Cambodia Outward Declaration)


ក្រសួងពាណិជ្ជកម្ម
លេខ ១៩-៦១ ផ្លូវក្រសួងពាណិជ្ជកម្ម (ផ្លូវ១១៣បេ)
ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨៦៦ ០៨៨/៨៦៦ ៨៧៨
ទូរសារលេខ: (៨៥៥) ២៣ ៨៦៦ ៨២៥
អ៊ីមែល: moccab@moc.gov.kh

- លិខិតឧទ្ទេសនាម និងផ្ទេរសិទ្ធិរបស់ក្រុមហ៊ុន ឱ្យតំណាងរបស់ខ្លួន

*ខ- ផលិតផលផ្សេងទៀត ក្រៅពីសម្លៀកបំពាក់ ផលិតផលវាយនភ័ណ្ឌ ស្បែកជើង និង Apparels*

- ពាក្យស្នើសុំវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញរបស់ក្រុមហ៊ុន
- មូលប្បទានប័ត្រថតចម្លង បញ្ជាក់ពីការបានបង់សោហ៊ុយរដ្ឋបាល និងកម្រៃគ្រប់គ្រងការនាំចេញ
- បង្កាន់ដៃបង់ប្រាក់កម្រៃសេវាសាធារណៈ
- វិក័យប័ត្រទិញ-លក់ (Invoice)
- តារាងបញ្ជាក់ពីការវេចខ្ចប់ (Packing List)
- អញ្ញត្តិប័ណ្ណដឹកជញ្ជូន (Bill of Lading)
- ប្រតិវេទន៍ចេញពីកម្ពុជា (Cambodia Outward Declaration)
- វិញ្ញាបនប័ត្របញ្ជាក់បរិមាណទំនិញនាំចេញ របស់អគ្គនាយកដ្ឋានកាំកុងត្រូល (CQ)
- ប្រតិវេទន៍គយ របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា (CD)
- ឯកសារពាក់ព័ន្ធរបស់ក្រុមហ៊ុន ដែលអាចបញ្ជាក់ពីប្រភពដើមទំនិញ
- អាជ្ញាប័ណ្ណនាំចេញ ( ចំពោះទំនិញ ដែលច្បាប់តម្រូវឱ្យមានអាជ្ញាប័ណ្ណនាំចេញ)
- លិខិតឧទ្ទេសនាម និងផ្ទេរសិទ្ធិរបស់ក្រុមហ៊ុន ឱ្យតំណាងរបស់ខ្លួន

*គ- ទំនិញជាផលិតផលសិប្បកម្មតូច និងកសិកម្ម*

- ពាក្យស្នើសុំវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញរបស់ក្រុមហ៊ុន
- មូលប្បទានប័ត្រថតចម្លង បញ្ជាក់ពីការបានបង់សោហ៊ុយរដ្ឋបាល និងកម្រៃគ្រប់គ្រងការនាំចេញ ប្រសិនមានការកំណត់ដោយបញ្ញត្តិ
- វិក័យប័ត្រទិញ-លក់ (Invoice)
- តារាងបញ្ជាក់ពីការវេចខ្ចប់ (Packing List)
- អញ្ញត្តិប័ណ្ណដឹកជញ្ជូន (Bill of Lading)
- ប្រតិវេទន៍ចេញពីកម្ពុជា (Cambodia Outward Declaration)
- វិញ្ញាបនប័ត្របញ្ជាក់បរិមាណទំនិញនាំចេញ របស់អគ្គនាយកដ្ឋានកាំកុងត្រូល (CQ)
- ប្រតិវេទន៍គយ របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា (CD)
- ឯកសារពាក់ព័ន្ធរបស់ក្រុមហ៊ុន ដែលអាចបញ្ជាក់ពីប្រភពដើមទំនិញ ( ករណី អង្ករ និង ផលិតផលកសិកម្ម ដែលមានលក្ខណៈរសើបមួយចំនួន)
- លិខិតឧទ្ទេសនាម និងផ្ទេរសិទ្ធិរបស់ក្រុមហ៊ុន ឱ្យតំណាងរបស់ខ្លួន

*ឃ- ទំនិញសម្លៀកបំពាក់ពណ៌ប៉ារ៉ា ពណ៌បៃតង (ត្រេអ៊ី) និង កាគី*


ក្រសួងពាណិជ្ជកម្ម
លេខ ១៩-៦១ ផ្លូវក្រសួងពាណិជ្ជកម្ម (ផ្លូវ១១៣បេ)
ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨៦៦ ០៨៨/៨៦៦ ៨៧៨
ទូរសារលេខ: (៨៥៥) ២៣ ៨៦៦ ៨២៥
អ៊ីម៉ែល: moccab@moc.gov.kh

នីតិវិធី និងឯកសារតម្រូវសម្រាប់ការនាំចេញ-នាំចូល ទំនិញប្រភេទនេះ ត្រូវអនុវត្តតាមប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ដែលស្ថិតជាធរមាន។

**២- ការនាំចេញតាមជើងយន្តហោះ (By Air)**

*ក- ទំនិញសម្លៀកបំពាក់ ផលិតផលវាយនភ័ណ្ឌ ស្បែកជើង និងសំភារៈប្រើប្រាស់ផ្សេងទៀត (Apparels) ដូចជា កាបូប មួក ជាដើម*

- ពាក្យស្នើសុំវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញរបស់ក្រុមហ៊ុន
- មូលប្បទានប័ត្រថតចម្លង បញ្ជាក់ពីការបានបង់សោហ៊ុយរដ្ឋបាល និងកម្រៃគ្រប់គ្រងការនាំចេញ
- បង្កាន់ដៃបង់ប្រាក់កម្រៃសេវាសាធារណៈ
- វិក័យប័ត្រទិញ-លក់ (Invoice)
- តារាងបញ្ជាក់ពីការវេចខ្ចប់ (Packing List)
- លិខិតឧទ្ទេសនាម និងផ្ទេរសិទ្ធិរបស់ក្រុមហ៊ុន ឱ្យតំណាងរបស់ខ្លួន

ក្រោយពេលទំនិញនាំចេញរួច ត្រូវជូនបន្ថែមនូវឯកសារ ដូចខាងក្រោម :

- អញ្ញត្តិប័ណ្ណដឹកជញ្ជូន (Airway Bill)
- កំណត់ហេតុរួមស្តីពីការត្រួតពិនិត្យទំនិញវាយនភ័ណ្ឌនាំចេញ របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និង អគ្គនាយកដ្ឋានកាំកុងត្រូល
- ប្រតិវេទន៍ចេញពីកម្ពុជា (Cambodia Outward Declaration)

*ខ- ទំនិញជាផលិតផលសិប្បកម្មតូច និងកសិកម្ម*

- ពាក្យស្នើសុំវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញរបស់ក្រុមហ៊ុន
- មូលប្បទានប័ត្រថតចម្លង បញ្ជាក់ពីការបានបង់សោហ៊ុយរដ្ឋបាល និងកម្រៃគ្រប់គ្រងការនាំចេញ ប្រសិនមានការកំណត់ដោយបញ្ញត្តិ
- វិក័យប័ត្រទិញ-លក់ (Invoice)
- តារាងបញ្ជាក់ពីការវេចខ្ចប់ (Packing List)
- លិខិតឧទ្ទេសនាម និងផ្ទេរសិទ្ធិរបស់ក្រុមហ៊ុន ឱ្យតំណាងរបស់ខ្លួន

ក្រោយពេលទំនិញនាំចេញរួច ត្រូវជូនបន្ថែមនូវឯកសារ ដូចខាងក្រោម :

- អញ្ញត្តិប័ណ្ណដឹកជញ្ជូនតាមផ្លូវអាកាស (Airway Bill)
- កំណត់ហេតុរួមស្តីពីការត្រួតពិនិត្យទំនិញនាំចេញ របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និង អគ្គនាយកដ្ឋានកាំកុងត្រូល
- ប្រតិវេទន៍ចេញពីកម្ពុជា (Cambodia Outward Declaration)


ក្រសួងពាណិជ្ជកម្ម
លេខ ១៩-៦១ ផ្លូវក្រសួងពាណិជ្ជកម្ម (ផ្លូវ១១៣បេ)
ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨៦៦ ០៨៨/៨៦៦ ៨៧៨
ទូរសារលេខ: (៨៥៥) ២៣ ៨៦៦ ៨២៥
អ៊ីម៉ែល: moccab@moc.gov.kh

**៣- ទំនិញសម្លៀកបំពាក់ ផលិតផលវាយនភ័ណ្ឌ ផលិតផលធ្វើពីស្បែក និងផលិតផលដទៃទៀត ដែលដឹកជញ្ជូនតាមរថយន្តឆ្លងកាត់ព្រំដែនកម្ពុជាទៅឡើងយន្តហោះនៅប្រទេសជិតខាង (Land-Air)**

- ពាក្យស្នើសុំវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញរបស់ក្រុមហ៊ុន
- មូលប្បទានប័ត្រថតចម្លង បញ្ជាក់ពីការបានបង់សោហ៊ុយរដ្ឋបាល និងកម្រៃគ្រប់គ្រងការនាំចេញ
- បង្កាន់ដៃបង់ប្រាក់កម្រៃសេវាសាធារណៈ
- វិក័យប័ត្រទិញ-លក់ (Invoice)
- តារាងបញ្ជាក់ពីការវេចខ្ចប់ (Packing List)
- របាយការណ៍របស់មន្ត្រីត្រួតពិនិត្យសង្វាក់ផលិតកម្ម និងផលិតផលនាំចេញ ដែលកំណត់ឱ្យមានយ៉ាង តិច ៥០% នៃបរិមាណសុំនាំចេញសរុប សំរាប់ទំនិញសុំនាំចេញក្នុងបរិមាណច្រើន, និងឱ្យបានយ៉ាង តិច ២០% សម្រាប់ទំនិញសុំនាំចេញក្នុងបរិមាណតិច ដែលរោងចក្រអាចផលិតរួចរាល់ដោយប្រើ ពេលវេលាត្រឹមតែ ០២ ថ្ងៃ។
- លិខិតឧទ្ទេសនាម និងផ្ទេរសិទ្ធិរបស់ក្រុមហ៊ុន ឱ្យតំណាងរបស់ខ្លួន

ក្នុងរយះពេលយ៉ាងយូរ ៣០ ថ្ងៃ បន្ទាប់ពីទទួលបានវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ អ្នកនាំចេញ ត្រូវប្រគល់ជូនបន្ថែម នូវឯកសារដូចខាងក្រោម :

- អញ្ញត្តិប័ណ្ណដឹកជញ្ជូនតាមផ្លូវអាកាស (Airway Bill)
- កំណត់ហេតុរួមស្តីពីការត្រួតពិនិត្យទំនិញវាយនភ័ណ្ឌនាំចេញ របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និង អគ្គនាយកដ្ឋានកាំកុងត្រូល
- ប្រតិវេទន៍ចេញពីកម្ពុជា (Cambodia Outward Declaration)

**៤- ការនាំចេញតាមរថយន្ត (By Truck)**

*ក- ទំនិញសម្លៀកបំពាក់ ផលិតផលវាយនភ័ណ្ឌ ស្បែកជើង និងសំភារៈប្រើប្រាស់ផ្សេងទៀត (Apparels) ដូចជា កាបូប មួក ជាដើម*

- ពាក្យស្នើសុំវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញរបស់ក្រុមហ៊ុន
- មូលប្បទានប័ត្រថតចម្លង បញ្ជាក់ពីការបានបង់សោហ៊ុយរដ្ឋបាល និងកម្រៃគ្រប់គ្រងការនាំចេញ
- បង្កាន់ដៃបង់ប្រាក់កម្រៃសេវាសាធារណៈ
- វិក័យប័ត្រទិញ-លក់ (Invoice)
- តារាងបញ្ជាក់ពីការវេចខ្ចប់ (Packing List)
- កំណត់ហេតុរួមស្តីពីការត្រួតពិនិត្យទំនិញវាយនភ័ណ្ឌនាំចេញ របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និង អគ្គនាយកដ្ឋានកាំកុងត្រូល



ក្រសួងពាណិជ្ជកម្ម
លេខ ១៩-៦១ ផ្លូវក្រសួងពាណិជ្ជកម្ម (ផ្លូវ១១៣បេ)
ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨៦៦ ០៨៨/៨៦៦ ៨៧៨
ទូរសារលេខ: (៨៥៥) ២៣ ៨៦៦ ៨២៥
អ៊ីមែល: moccab@moc.gov.kh

- ប្រតិវេទន៍ចេញពីកម្ពុជា (Cambodia Outward Declaration)
- លិខិតឧទ្ទេសនាម និងផ្ទេរសិទ្ធិរបស់ក្រុមហ៊ុន ឱ្យតំណាងរបស់ខ្លួន

*ខ- ទំនិញជាផលិតផលសិប្បកម្មតូច និងកសិកម្ម*

- ពាក្យស្នើសុំវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញរបស់ក្រុមហ៊ុន
- វិក័យប័ត្រទិញ-លក់ (Invoice)
- តារាងបញ្ជាក់ពីការវេចខ្ចប់ (Packing List)
- អញ្ញត្តិប័ណ្ណដឹកជញ្ជូន (Bill of Lading)
- ប្រតិវេទន៍ចេញពីកម្ពុជា (Cambodia Outward Declaration)

ក្រោយពេលទំនិញនាំចេញរួច ត្រូវជូនបន្ថែមនូវឯកសារ ដូចខាងក្រោម :

- វិញ្ញាបនប័ត្របញ្ជាក់បរិមាណទំនិញនាំចេញ របស់អគ្គនាយកដ្ឋានកាំកុងត្រូល (CQ)
- ប្រតិវេទន៍គយរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (CD)
- មូលប្បទានប័ត្រថតចម្លង បញ្ជាក់ពីការបានបង់សោហ៊ុយរដ្ឋបាល
- ឯកសារភស្តុតាង បញ្ជាក់ពីប្រភពដើមដែលក្រុមហ៊ុនទិញទំនិញបន្ត (ក្នុងករណីអង្ករ និងផលិតផលកសិកម្ម ដែលមានលក្ខណៈរសើបមួយចំនួន)

**ប្រការ ៥.-**

ត្រូវបានកំណត់ពេលវេលាសរុបអតិបរមា ចំនួន ១៦ ម៉ោង នៃម៉ោងធ្វើការ សម្រាប់នាយកដ្ឋានជំនាញនៅក្រសួងពាណិជ្ជកម្ម ច្រកចេញ-ចូលតែមួយប្រចាំនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងតំណាងរបស់ក្រសួងពាណិជ្ជកម្ម ប្រចាំនៅរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ដំណើរការចេញវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញដោយពេលវេលានេះ មិនរាប់បញ្ចូលនូវពេលវេលាសម្រាប់រៀបចំឯកសារ និងបែបបទដោយក្រុមហ៊ុន ឬតំណាងស្របច្បាប់របស់ក្រុមហ៊ុនឡើយ។ ពេលវេលាសរុបកំណត់ខាងលើ ត្រូវបានបែងចែកជាពេលវេលាជាក់ស្តែងសម្រាប់មន្ត្រីពាក់ព័ន្ធក្នុងខ្សែសង្វាក់ការងារ ហើយអាចកែសម្រួលបានដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម តាមការចាំបាច់ និងនៅពេលដែលប្រព័ន្ធស្វ័យប្រវត្តិកម្មនៃការចេញវិញ្ញាបនប័ត្រប្រភពដើមទំនិញ ត្រូវបានដាក់ឱ្យដំណើរជាផ្លូវការ ។

**ប្រការ ៦.-**

ការធ្វើអធិការកិច្ចលើសង្វាក់ផលិតកម្ម និងផលិតផលនាំចេញ ត្រូវធ្វើឡើងដោយមន្ត្រីជំនាញនៃក្រសួងពាណិជ្ជកម្ម នៅទីតាំងផលិតកម្ម កន្លែងប្រមូលទិញ ឬ ឃ្លាំងស្តុកទំនិញ តាមការស្នើសុំរបស់ក្រុមហ៊ុន ឬអ្នកនាំចេញ ឬតាមការចាំបាច់របស់នាយកដ្ឋានជំនាញ ដោយ :

- ចំពោះទំនិញកសិកម្ម និងផលិតផលកែច្នៃពីកសិផល ៖ ការងារអធិការកិច្ច ត្រូវធ្វើមុនពេលដាក់ពាក្យស្នើសុំវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ។ ក្នុងករណីចាំបាច់ ក្រុមហ៊ុន ឬអ្នកនាំចេញ ដែលធ្លាប់បានអនុញ្ញាតឱ្យនាំចេញច្រើនលើកហើយ អាចស្នើមកមន្ត្រីក្រសួងពាណិជ្ជកម្ម សុំធ្វើអធិការកិច្ច ក្រោយពេលដាក់ពាក្យស្នើ សុំវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ។
- ចំពោះទំនិញជាសម្លៀកបំពាក់ វាយនភ័ណ្ឌ និងផលិតផលធ្វើពីស្បែក ៖ ការងារអធិការកិច្ច ត្រូវធ្វើក្រោយពេលដាក់ពាក្យស្នើសុំវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ តែមិនត្រូវហួស ៣០ ថ្ងៃ ដោយគិតចាប់ពីថ្ងៃចេញ វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញឡើយ ។

**ប្រការ ៧.-**

ការប្រមូលចំណូលពីការបង់សោហ៊ុយរដ្ឋបាល (Administrative Fee) ត្រូវធ្វើតាមរយៈមូលប្បទានប័ត្រ នៅនាយកដ្ឋានគណនេយ្យនៃក្រសួងពាណិជ្ជកម្ម ស្របតាមប្រកាសរួមលេខ ៩៨៥ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម។

ការប្រមូលចំណូលពីការបង់កម្រៃគ្រប់គ្រង ការនាំចេញ (Export Management Fee - EMF) ត្រូវអនុលោមតាមប្រកាសរួម រវាងក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលស្ថិតជាធរមាន។

**ប្រការ ៨.-**

ការបង់កម្រៃសេវាសាធារណៈ ត្រូវធ្វើឡើងដោយអនុលោមតាមប្រកាសរួមលេខ ៩៨៥ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម។

**ប្រការ ៩.-**

អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ មានតួនាទីជាចំណុចកណ្តាល (Focal Point) ដោយមាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មជាលេខាធិការដ្ឋាន ក្នុងការពិនិត្យស្រាវជ្រាវ ផ្ទៀងផ្ទាត់ ឆ្លើយបំភ្លឺពីភាពត្រឹមត្រូវរបស់វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ ក្នុងករណីមានការចោទសួរពីប្រទេសនាំចូល។ នីតិវិធីលម្អិតទាក់ទងនឹងការធ្វើអធិការកិច្ច និងការរៀបចំឯកសារឆ្លើយបំភ្លឺ នឹងកំណត់ដោយប្រកាសដោយឡែករបស់ក្រសួងពាណិជ្ជកម្ម។

**ប្រការ ១០.-**

នីតិវិធីនៃការផ្ទៀងផ្ទាត់សន្និធិ រវាងបរិមាណវត្ថុធាតុដើមនាំចូល និងទំនិញត្រូវនាំចេញ ត្រូវអនុវត្តនៅនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ស្របតាមខ្លឹមសារអនុក្រឹត្យ លេខ ៩១ អនក្រ.បក ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៧, សេចក្តី ណែនាំរបស់ក្រសួងពាណិជ្ជកម្ម លេខ 00៥១ MOC/SM ២០១១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ និងគោលនយោបាយ សម្រួលពាណិជ្ជកម្មរបស់រាជរដ្ឋាភិបាល។


ក្រសួងពាណិជ្ជកម្ម
លេខ ១៩-៦១ ផ្លូវក្រសួងពាណិជ្ជកម្ម (ផ្លូវ១១៣បេ)
ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨៦៦ ០៨៨/៨៦៦ ៨៧៨
ទូរសារលេខ: (៨៥៥) ២៣ ៨៦៦ ៨២៥
អ៊ីម៉ែល: moccab@moc.gov.kh

**ប្រការ ១១.-**

អ្នកនាំចេញត្រូវប្រញាប់ប្រញាល់មកដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ និងបំពេញកាតព្វកិច្ចបង់ចំណូលនានាចូលថវិកាជាតិ មិនឱ្យលើសពី ៣០ ថ្ងៃ បន្ទាប់ពីទំនិញបានចេញរួច ដោយរាប់ពីកាលបរិច្ឆេទកត់ត្រាលើកំណត់ហេតុរួម រវាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និង អគ្គនាយកដ្ឋានកាំកុងត្រូល ។

អ្នកនាំចេញដែលមានការយឺតយ៉ាវ ឬខកខាន មិនបានមកបំពេញបែបបទស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ នឹងត្រូវទទួលការពិន័យ ឬផ្អាកការនាំចេញជាបណ្ដោះអាសន្ន ។ ក្រសួងពាណិជ្ជកម្មនឹងពិនិត្យលទ្ធភាពអនុញ្ញាតឱ្យ នាំចេញវិញនៅពេលដែលក្រុមនោះ បានបំពេញបែបបទសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ និងបង់ចំណូលនានា និង បង់ប្រាក់ពិន័យគ្រប់ចំនួន និងរួចរាល់ តាមការកំណត់ ។

**ប្រការ ១២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១៣.-**

នាយិកាខុទ្ទកាល័យ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន តំណាងរបស់ក្រសួងពាណិជ្ជកម្ម ប្រចាំរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសនានាទូទាំងប្រទេស និងអង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៣

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**ចម្លងជូន**

- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- -ទីស្ដីការគណៈរដ្ឋមន្ត្រី
- -អាជ្ញាធរសវនកម្មជាតិ
- -អង្គភាពប្រឆាំងអំពើពុករលួយ
- -ដូចប្រការ ១៣ " ដើម្បីអនុវត្ត"
- -ឯកសារ-កាលប្បវត្តិ



ក្រសួងពាណិជ្ជកម្ម
លេខ ១៩-៦១ ផ្លូវក្រសួងពាណិជ្ជកម្ម (ផ្លូវ១១៣បេ)
ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨៦៦ ០៨៨/៨៦៦ ៨៧៨
ទូរសារលេខ: (៨៥៥) ២៣ ៨៦៦ ៨២៥
អ៊ីម៉ែល: moccab@moc.gov.kh